ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ7-02-186 ប្រ.ក

# ប្រកាស
## ស្តីពី
## ចំណាត់ថ្នាក់និងសំវិធានធនលើឥណទាន
## អនុវត្តចំពោះធនាគារឯកទេសឥណទានជនបទនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិ នៃ កម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខធ ៧០០-០៦ ប្រ.ក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមការឯកភាពរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ។

## ស ំ រ េ ច

**ប្រការ ១.-**

ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវរៀបចំប្រព័ន្ធពត៌មានគណនេយ្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីអាចមានលទ្ធភាពផ្តល់ពត៌មានជាអចិន្ត្រៃយ៍ដល់ធនាគារជាតិនៃកម្ពុជា ។


ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណត្រូវធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជា៤ថ្នាក់ ដោយផ្អែកទៅលើស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់ និងឥណប្បទានប្រតិទាននៃការទូទាត់សងប្រាក់ដើមនិងការប្រាក់ ដូចខាងក្រោម :

- បំណុលស្តង់ដារ: ស្ថានភាពហិរញ្ញវត្ថុល្អ និងការសងទៀងទាត់នៃប្រាក់ដើមនិងការប្រាក់ ។
- បំណុលក្រោមស្តង់ដារ : ការសងប្រាក់ដើមនិង/ឬ ការប្រាក់ហួសកាលកំណត់៣០ថ្ងៃឬច្រើនជាង ។
- បំណុលសង្ស័យ : ការសងប្រាក់ដើម និង/ឬ ការប្រាក់ហួសកាលកំណត់ ដូចខាងក្រោម÷
  - ៦០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន១ឆ្នាំ ឬតិចជាង១ឆ្នាំ ។
  - ១៨០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន លើសពី១ឆ្នាំ ។
- បំណុលបាត់បង់ : ការសងប្រាក់ដើម និង/ឬ ការប្រាក់ហួសកាលកំណត់ ដូចខាងក្រោម÷
  - ៩០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន១ឆ្នាំ ឬតិចជាង១ឆ្នាំ ។
  - ៣៦០ថ្ងៃ ឬច្រើនជាង ក្នុងករណីឥណទានមានឥណប្រតិទាន លើសពី១ឆ្នាំ ។

**ប្រការ ៣.-**

ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើសំវិធានធនលើឥណទានដូចខាងក្រោម÷

- បំណុលក្រោមស្តង់ដារ :១០% ដោយមិនគិតដល់តំលៃទ្រព្យសម្បត្តិដែលបានដាក់បញ្ចាំ លើកលែងតែសាច់ប្រាក់
- បំណុលសង្ស័យ : ៣០%ដោយមិនគិតដល់តំលៃទ្រព្យសម្បត្តិដែលបានដាក់បញ្ចាំ លើកលែងតែសាច់ប្រាក់
- បំណុលបាត់បង់ : ១០០% បើគ្រឹះស្ថានអាចបង្ហាញភស្តុតាងតាមករណីនិមួយៗនូវតំលៃទីផ្សារជាក់ស្តែងនៃទ្រព្យសម្បត្តិដែលបានដាក់ជាវត្ថុបញ្ចាំ និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ចំនួនឥណទានដែលពុំមានសំភារៈធានា ត្រូវធ្វើសំវិធានធន ។

សំវិធានធនត្រូវបានគណនាតាមសមតុល្យឥណទានដែលបានធ្វើចំណាត់ថ្នាក់ ដោយមិនគិតបញ្ចូលការប្រាក់បង្គរ ។ សំវិធានធនត្រូវបានកត់ត្រាក្នុងគណនីរបស់គ្រឹះស្ថាន ហើយគិតបញ្ចូលទៅក្នុងគណនីចំណេញ-ខាត ក្នុងខែដែលឥណទានត្រូវបានធ្វើចំណាត់ថ្នាក់ក្រោមស្តង់ដារ ។

**ប្រការ ៤.-**

ការប្រាក់បង្គរលើឥណទានត្រូវកត់ត្រាជាចំណូលក្នុងគណនីចំណេញ-ខាតនៅពេលកត់ត្រាបង្គរ ។ ប៉ុន្តែចំពោះឥណទានដែលបានធ្វើចំណាត់ថ្នាក់ក្រោមស្តង់ដារ និងការប្រាក់បង្គរដែលមិនបានសងពេលនេះនឹងត្រូវផ្ទេរចេញពីគណនីចំណេញ-ខាត ហើយយកទៅចុះឥណទានក្នុងគណនីព្យួរទុក ។ ដូចគ្នានេះដែរ ការប្រាក់បង្គរលើឥណទានណាមួយបន្ទាប់ពីបានធ្វើចំណាត់ថ្នាក់ក្រោមស្តង់ដារនឹងត្រូវចុះឥណទានក្នុងគណនីព្យួរទុក ។

**ប្រការ ៥.-**

គ្រឹះស្ថានណាដែលមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៦.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់ធនាគារឯកទេសឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២

ទេសាភិបាល

ជា ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"